# បោះឆ្នោតឃុំសង្កាត់ ២០២២ និងបញ្ហាប្រឈម

ដោយ៖ លោក អ៊ុច លាង អ្នកសិក្សាស្រាវជ្រាវនៃនាយកដ្ឋានសិក្សាអាស៊ី អាហ្វ្រិក និងមជ្ឈិមបូព៌ា
នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា

ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ត្រូវបានប្រមុខរាជរដ្ឋាភិបាល កំណត់ជ្រើសយក ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ជាកាលបរិច្ឆេទនៃការបោះឆ្នោត។ នេះបើយោងតាមសេចក្តីសម្រេច របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១កន្លងទៅ។

យោងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានអនុម័តកាល កាលពីឆ្នាំ២០១៥ បានបញ្ជាក់ថា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវធ្វើឡើងជារៀងរាល់ ៥ឆ្នាំម្តង ហើយការបោះឆ្នោតនេះ ត្រូវធ្វើឡើងនៅថ្ងៃតែមួយជាមួយគ្នា។ ការបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងរយៈពេល ៩ខែ យ៉ាងតិចមុនថ្ងៃបោះឆ្នោត។

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវកាន់មុខតំណែងរបស់ខ្លួន រហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស។ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែលបានចុះឈ្មោះ នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំសង្កាត់នោះមានសិទ្ធិបោះឆ្នោតតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសំងាត់។ អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់តែមួយប៉ុណ្ណោះ។

គួររំលឹកផងដែរថា ចាប់តាំងពីរដ្ឋប្រហារឆ្នាំ១៩៧០មក ប្រទេសកម្ពុជា បានជួបប្រទះនឹងសង្គ្រាមស៊ីវិលជាបន្តបន្ទាប់ អស់រយៈពេលជាច្រើនទសវត្សរ៍កន្លងទៅ។ នៅឆ្នាំ១៩៩១ ភាគីនៅក្នុងជម្លោះបានឈានដល់ការចុះកិច្ចព្រមព្រៀងឈប់បាញ់ និងឈានទៅដល់ការបោះឆ្នោតជាតិ ដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (ហៅកាត់ថា អ៊ុនតាក់) ក្រោមកិច្ចសហការ ជាមួយនឹងក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា (ហៅកាត់ថា អេសអិនស៊ី) នាឆ្នាំ១៩៩៣។

រហូតដល់នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី១ ត្រូវបានធ្វើឡើងជាសកល និងដោយផ្ទាល់ សម្រាប់ឃុំ និងសង្កាត់ បន្ទាប់មកអនុវត្តជាបន្តបន្ទាប់រៀងរាល់៥ឆ្នាំម្តង គឺ អាណត្តិទី២(២០០៧) អាណត្តិទី៣(២០១២) អាណត្តិទី៤(២០១៧) និងអាណត្តិទី៥(២០២២)

ដែលបានជ្រើសយកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ជាថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងប្រកាស លទ្ធផលបណ្ដោះអាសន្ន។[១]

អ្នកនាំពាក្យ គ.ជ.ប លោក ហង្ស ពុទ្ធា បានលើកឡើងផងដែរថា គណៈកម្មាធិការ បាននិងកំពុងប្រឹងប្រែងយ៉ាងខ្លាំងដើម្បីធានាបាននូវលទ្ធផលដ៏ត្រឹមត្រូវនៃការបោះឆ្នោត ដែលឆ្លុះបញ្ចាំងពីឆន្ទៈ របស់អ្នកបោះឆ្នោត និងការរំពឹងទុកនៃមេដឹកនាំដែលពួកគេបានជ្រើសរើស។

សូមរំលឹកផងដែរថា កាលពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ កន្លងទៅ គណបក្សនយោបាយដែលចូលរួម ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ នៅទូទាំងប្រទេសដែលមាន២៥ខេត្តក្រុង មានគណបក្ស ចូលរួមសរុបចំនួន១២ (១-គណបក្សប្រជាជនកម្ពុជា, ២-គណបក្សសង្គ្រោះជាតិ, ៣-គណបក្សហ្វ៊ុន ស៊ិន ប៉ិក, ៤-គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ, ៥-គណបក្ស ខ្មែររួបរួមជាតិ, ៦-គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, ៧-គណបក្សសញ្ជាតិកម្ពុជា, ៨-គណបក្សប្រជាធិបតេយ្យ មូលដ្ឋាន, ៩-គណបក្ស សាធារណរដ្ឋប្រជាធិបតេយ្យ, ១០-គណបក្សយុវជនកម្ពុជា, ១១-គណបក្ស អំណាចខ្មែរ, និង ១២-គណបក្ស ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា)។ នៅក្នុងការបោះឆ្នោតកន្លងទៅនោះ មានតែគណបក្សចំនួន២ ប៉ុណ្ណោះដែលមានឥទ្ធពលក្នុងការបោះឆ្នោត គឺគណបក្សប្រជាជនកម្ពុជា ទទួលបាន៣.៥៤ លានសំឡេង និងទទួលបានតំណែងមេឃុំ ចំនួន១១៥៦ និងអាសនៈក្រុមប្រឹក្សា៦៥០៣ ខណៈដែលគណបក្សសង្គ្រោះជាតិទទួលបាន៣,០៦ លានសំឡេង និងទទួលបានតំណែងមេឃុំចំនួន៤៨៩ និងអាសនៈក្រុមប្រឹក្សាចំនួន៥០០៧។[២]

ប៉ុន្តែនៅពេលដែលគណបក្ស សង្គ្រោះជាតិត្រូវបានរំលាយ ដោយតុលាការកំពូល កាលពីខែវិច្ឆិកា ឆ្នាំ២០១៧ ពីបទរួមចំណែកជា មួយបរទេសក្នុងផែនការផ្តួលរំលំរដ្ឋាភិបាល អាសនៈ ក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់ ត្រូវបានចែកចាយ ឱ្យទៅគណបក្សផ្សេងទៀត។ គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈក្រុមប្រឹក្សាចំនួន៤៥៤៨ គណបក្សហ៊្វុនស៊ិនប៉ិចទទួលអាសនៈក្រុមប្រឹក្សា ចំនួន២៣៩ គណបក្សខ្មែររួបរួមជាតិទទួលបានអាសនៈក្រុមប្រឹក្សាចំនួន២០១ គណបក្សសញ្ជាតិកម្ពុជាត្រូវបានផ្តល់

---

[១] The Natioanl Election Committee(NEC), "ប្រតិទិនបោះឆ្នោត",
https://www.nec.gov.kh/khmer/taxonomy/term/253, accessed date 8-August-2021 at 10 AM)

[២] The Natioanl Election Committee(NEC), "តារាងគណបក្សនយោបាយទទួលបានអាសនៈ នៃលទ្ធផលផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧",
https://www.nec.gov.kh/khmer/content/4457, accessed date 8-August-2021 at 10 AM)

អាសនៈក្រុមប្រឹក្សាចំនួន១០ គណបក្សយុវជនកម្ពុជា ទទួលបានអាសនៈក្រុមប្រឹក្សាចំនួន៣ និងគណបក្សប្រជាធិបតេយ្យមូលដ្ឋានទទួលបានអាសនៈក្រុមប្រឹក្សាចំនួន៣។[៣]

សម្រាប់ការបោះឆ្នោត ជ្រើសតាំងសមាជិកក្រុមប្រឹក្សា ឃុំសង្កាត់ អាណត្តិទី៤ នាឆ្នាំ២០១៧ កន្លងទៅ យើងសង្កេតឃើញថា ប្រព្រឹត្តទៅដោយរលូន ប្រកបដោយសុខសន្តិភាព និងមានភាពល្អប្រសើជាងពេលបោះឆ្នោតមុនៗ និងមានអ្នកបោះឆ្នោតប្រមាណ ៩០.៣៧% បានចេញទៅបោះឆ្នោត បើធៀបនឹងចំនួនអ្នកដែលបានចុះឈ្មោះបោះឆ្នោត និងប្រកបដោយទឹកមុខរីករាយ គ្មានការភិតភ័យ និងភ័យខ្លាចនេះបើយោងតាមសេចក្តីថ្លែងការណ៍ របស់ គ.ជ.ប អាណត្តិទី៤ ឆ្នាំ២០១៧។[៤]

ចំណែកអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ (Human Rights Watch) បែរជា អះអាងថា ការបោះឆ្នោតឃុំ-សង្កាត់នៅប្រទេសកម្ពុជា កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ បានប្រព្រឹត្តទៅក្នុងបរិយាកាសគំរាមកំហែងទៅដល់សិទ្ធិបញ្ចេញមតិ និងការចូលរួមក្នុងនយោបាយ ដែលអាចចាត់ទុកការបោះឆ្នោតនេះថា មិនបានធ្វើឡើងដោយសេរី និងយុត្តិធម៌នោះទេ។ ការបោះឆ្នោតនេះបានធ្វើឡើងស្របពេលដែលសមាជិក និងសកម្មជនគណបក្សប្រឆាំងរាប់សិបនាក់កំពុងជាប់ពន្ធនាគារ ក្នុងនោះរួមមានទាំងសមាជិករដ្ឋសភា ព្រឹទ្ធសភា និងមន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ផងដែរ បន្ទាប់ពីពួកគេត្រូវចោទប្រកាន់ក្រោមហេតុផលនយោបាយ ដោយតុលាការគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា។ មានមនុស្សជាច្រើនទៀត កំពុងរងការគំរាមកំហែងពីបទចោទប្រកាន់ដូចគ្នានេះ ខណៈ

---

[៣] Khmer Times, "ការបោះឆ្នោតឃុំ-សង្កាត់នឹងធ្វើឡើងនៅខែមិថុនាឆ្នាំក្រោយ", March 5, 2021, https://www.khmertimeskh.com/50821266/ករបេធនតឃ-សងកតន/, accessed date 8-August-2021 at 10 PM)

[៤] Fresh News Asia, "គ.ជ.ប ចេញសេចក្តីថ្លែងការណ៍សោកស្តាយយ៉ាងខ្លាំង ចំពោះការវាយតម្លៃខុស ធ្វើឲ្យសាធារណជនយល់ច្រឡំលើដំណើរការនិងលទ្ធផលបោះឆ្នោត, អ្នកបោះឆ្នោត៩០.៣៧% បានទៅបោះឆ្នោតជាមួយទឹកមុខរីករាយ គ្មានការបំផិតបំភ័យ និងគ្មានការភ័យខ្លាច", June 27, 2017,http://m.freshnewsasia.com/index.php/en/localnews/58353-2017-06-27-11-45-27.html, accessed date 8-August-2021 at 10 PM)

ដែល លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំង (គណបក្សសង្គ្រោះជាតិ - CNRP) នៅតែនិរទេសខ្លួនឱ្យនៅក្រៅប្រទេស បន្ទាប់ពីបានរងការចោទប្រកាន់ជាច្រើនករណី។[៥]

ចំណែក នាយកប្រចាំតំបន់អាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ លោក ប្រ៊ែដ អាដាម (Brad Adams) បានថ្លែងយ៉ាងដូច្នេះថា៖ "វាមិនមែនជាការបោះឆ្នោតតាមបែបប្រជាធិបតេយ្យឡើយ ប្រសិនបើគណបក្សកាន់អំណាចគ្រប់គ្រងស្ថាប័នដែលពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ ប្រព័ន្ធផ្សព្វផ្សាយស្ថិត ក្រោមគ្រប់គ្រងដោយគណបក្សកាន់អំណាច ហើយសមាជិកគណបក្សប្រឆាំងជាច្រើន ត្រូវប្រឈមនឹងការគំរាមកំហែងដល់អាយុជីវិតពីសំណាក់លោកនាយករដ្ឋមន្ត្រី។ ដូច្នោះ វាគ្មានស្តង់ដារទាល់តែសោះ ដែលអាចកំណត់ថា ការបោះឆ្នោតនោះធ្វើឡើងដោយសេរី ត្រឹមត្រូវ ឬយុត្តិធម៌ បើបញ្ហាទាំងអស់នេះនៅតែបន្តកើតមាន។[៦]

យោងតាមប្រតិទិនរបស់ គ.ជ.ព សម្រាប់ការបោះឆ្នោតជ្រើសរើសសមជិកក្រុមប្រឹក្សា ឃុំសង្កាត់ អាណត្តិទី៥ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខ ជាថ្ងៃបោះឆ្នោតផង រាប់សន្លឹកឆ្នោតផង និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោតផង។ នៅថ្ងៃទី៥ឬ៦ ខែមិថុនា ឆ្នាំ២០២២ ជាការប្រកាសផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតដោយ គ.ជ.ប។

កាលពីពេលកន្លងទៅ ដោយសារជំងឺកូវីដ-១៩ បានរីករាលដាលនៅក្នុងប្រទេសកម្ពុជាកាន់តែកើនឡើង និងដើម្បីទប់ស្កាត់ការឆ្លង ជំងឺកូវីដ-១៩ នេះ គ.ជ.ប សម្រេចលើកពេលជាច្រើនសារ និងក៏បានឈានទៅដល់លុបចោល ការរៀបចំបោះឆ្នោតសាកល្បង ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ តែម្តង ប៉ុន្តែការបោះផ្លូវការនៅតែបន្ត ដើម្បីរក្សានិរន្តរភាពរាល់៥ឆ្នាំម្តង។ គណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោត (គ.ជ.ប) ក៏បានលើកឡើងផងដែរថា គណៈកម្មាធិការនឹងត្រៀមរៀបចំការបោះឆ្នោត មួយដែល ប្រកបដោយ សេរីនិងយុត្តិធម៌ ហើយគណបក្សនយោបាយនានា ក៏បានប្រកាសផងដែរថា ពួកគេបាន ត្រៀមខ្លួនរួចជាស្រេច ដើម្បីប្រកួតប្រជែងយកអាសនៈក្នុងការបោះឆ្នោតអាណត្តិទិ៥នេះ។

---

[៥] Human Rights Watch, "ប្រទេសកម្ពុជា ៖ ការបោះឆ្នោតឃុំ-សង្កាត់មិនបានធ្វើឡើងដោយសេរី ឬយុត្តិធម៌ទេ", June 12, 2017, https://www.hrw.org/km/news/2017/06/12/304876, accessed date 8-August-2021 at 10 PM)

[៦] Human Rights Watch, "ប្រទេសកម្ពុជា ៖ ការបោះឆ្នោតឃុំ-សង្កាត់មិនបានធ្វើឡើងដោយសេរី ឬយុត្តិធម៌ទេ", June 12, 2017,https://www.hrw.org/km/news/2017/06/12/304876, accessed date 8-August-2021 at 10 PM)

## ស្ថានភាពផ្ទៃក្នុងប្រទេស

ឆ្នាំ២០២២ ខាងមុខ រាជរដ្ឋាភិបាលកម្ពុជា មានគម្រោងចាក់វ៉ាក់សាំងជូនពលរដ្ឋឱ្យបាន ១០០ភាគរយ នៅទូទាំងប្រទេស ហើយក៏បានចាប់ផ្តើមចាក់វ៉ាក់សាំង បង្ការដល់កុមារអាយុចាប់ពី១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ កាលពីដើមខែកក្កដាកន្លងទៅ ដើម្បីកាត់បន្ថយការឆ្លង និងរីករាលដាល និងដើម្បីអាចឈានទៅដល់ការគ្រប់គ្រងបានទាំងស្រុង។ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខ ប្រសិនបើស្ថានភាពនៃការរីករាលដាលនៃវីរុសកូវីដ-១៩ នៅតែបន្តមិនអាចគ្រប់គ្រងបាន នោះការរៀបចំបោះឆ្នោតរបស់ គ.ជ.ប និងការចេញទៅបោះឆ្នោតរបស់ពលរដ្ឋនៅតែបញ្ហាប្រឈម។

មួយវិញទៀត ក្រោយប្រកាសកំណត់ពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំសង្កាត់ អាណត្តិទី៥ ប្រមុខរដ្ឋាភិបាលកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងតាមរយៈសារលិខិត អបអរខួបលើកទី៧៦ឆ្នាំ នៃថ្ងៃកំណើតនគរបាលជាតិថ្ងៃទី១៦ ខែឧសភា ថា ដំណើរការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ ខាងមុខគឺជាគោលដៅ នៃការប៉ុនប៉ងវាយប្រហាររបស់ក្រុមប្រឆាំង។ សម្តេចក៏បានបញ្ជាឱ្យកម្លាំងនគរបាលជាតិ ត្រូវបន្តពង្រឹងស្មារតី រក្សាឱ្យបាននូវស្ថិរភាព និងបង្ក្រាបឱ្យទាន់ពេលវេលារាល់សកម្មភាពរបស់ក្រុមនេះ។ ស្ថានការណ៍នៅពេលខាងមុខ ទោះបីតិចឬច្រើន ផ្ទាល់ឬប្រយោលក្តី គឺសុទ្ធតែមានផលប៉ះពាល់ដល់សន្តិសុខផ្ទៃក្នុងយ៉ាងពិតប្រាកដ។[៧]

អ្នកនយោបាយរបស់អតីតបក្សប្រឆាំង លោក មាជ សុវណ្ណារ៉ា លើកឡើងថា សាររបស់ សម្តេច ហ៊ុន សែន ដែលបញ្ជាឱ្យអាជ្ញាធរមានសមត្ថកិច្ចត្រៀមបង្ក្រាបក្រុមប្រឆាំង គឺជាការបង្ហាញថា ការរំលាយគណបក្សសង្គ្រោះជាតិ គឺជាកំហុសដ៏ធំមួយទៅវិញ ហើយថាសំឡេងរបស់បក្សប្រឆាំង នៅតែមានឥទ្ធិល ទាំងលើពលរដ្ឋខ្មែរ និងលើឆាកអន្តរជាតិ។ ហើយនេះអាចជាចេតនាមួយក្នុងការពន្យាពេលបោះឆ្នោត ឬជាចេតនាចង់ឱ្យមានបក្សប្រឆាំងចូលរួមការបោះឆ្នោត ខណៈដែលគណបក្សនយោបាយជាច្រើនទៀត ដែលចូលរួមការបោះឆ្នោត កន្លងមកមិនទទួលអាសនៈទាល់តែសោះនៅក្នុងរដ្ឋសភា។[៨]

មកទល់ពេលនេះ មន្ត្រីជាន់ខ្ពស់នៃអតីតគណបក្សប្រឆាំងចំនួន២០រូប ដែលត្រូវបានផ្តល់សិទ្ធិឱ្យធ្វើនយោបាយឡើងវិញ ហើយពួកគេបានបង្កើតគណបក្សផ្សេងរៀងៗខ្លួន។ ការចេញទៅបង្កើតបក្សបែប

---

[៧] FRI, "លោក ហ៊ុន សែន៖ការបោះឆ្នោតឃុំ-សង្កាត់ពេលខាងមុខគឺជាគោលដៅប៉ងវាយប្រហាររបស់ក្រុមប្រឆាំង", May 16, 2017, https://rfi.my/7Ovc, accessed date 8-August-2021 at 11 PM)

[៨] RFI, "សេចក្តីព្រាងច្បាប់ដាក់ទណ្ឌកម្មមន្ត្រីកម្ពុជាត្រូវបានសភាអាមេរិកលើកមកពិនិត្យអនុម័តឡើងវិញ", August 1, 2021,https://rfi.my/7cXI, accessed date 8-August-2021 at 11 PM)

ពាយប៉ាយដោយមន្ត្រីនៃអតីតបក្សសង្គ្រោះជាតិនេះ មិនត្រូវបានគាំទ្រដោយអតីតមេដឹកនាំទាំង២រូបគឺ លោក សម រង្ស៊ី និង លោក កឹម សុខា នោះទេ។ ហើយមេដឹកនាំទាំង២រូបនេះទៀតសោត ក៏ត្រូវបានគេ សង្កេតឃើញជាទូទៅថា លែងមានទំនាក់ទំនងស្អិតរមួតដូចមុនទៀតហើយ។[៩]

អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន កាលពីព្រឹកថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១នេះ បាននិយាយថា គណបក្សប្រជាជនកម្ពុជា គ្មានការភ័យព្រួយអ្វីបន្តិចនោះទេ ចំពោះ គម្រោងបង្រួមបង្រួមបក្សឡើងវិញរបស់អតីតមន្ត្រីជាន់ខ្ពស់នៃអតីតគណបក្សសង្គ្រោះជាតិ។ ផ្ទុយទៅវិញ លោកថា គណបក្សប្រជាជន តែងតែរង់ចាំគណបក្សនយោបាយណាដែលតាំងខ្លួនខ្លាំង ក្នុងការប្រកួត ប្រជែងលើឆាក នយោបាយនៅកម្ពុជា។ ការលើកឡើងរបស់ លោក សុខ ឥសាន ដូច្នេះ គឺបន្ទាប់ពី សហស្ថាបនិកគណបក្សកែទម្រង់កម្ពុជា និងជាអតីតមន្ត្រីជាន់ខ្ពស់នៃអតីតគណបក្សសង្គ្រោះជាតិ លោក អ៊ូ ចាន់រ័ត្ន បានលើកឡើងថា ការរួបរួមគ្នាក្រោមស្លាកបក្ស តែមួយឡើងវិញ គឺជាឱកាសបង្កើនកម្លាំង និងឥទ្ធិពលលើ ឆាកនយោបាយកម្ពុជា និងក៏អាចជាសម្លេង ប្រឆាំងជាមួយបក្សកាន់អំណាច។ សូម បញ្ជាក់ថា រហូតមកទល់ពេលនេះ មន្ត្រីជាន់ខ្ពស់នៃអតីតគណបក្សសង្គ្រោះជាតិ ចំនួនជាង២៤រូប ហើយ ដែល ទទួលបានសិទ្ធិ ធ្វើនយោបាយឡើងវិញ និងដោយបានបង្កើតគណបក្ស ចំនួន៦ថែមទៀត។ គណបក្ស ទាំង៦នេះរួមមាន គណបក្សខ្មែរអភិរក្ស គណបក្សខ្មែរស្រលាញ់ជាតិ គណបក្សកែទម្រង់កម្ពុជា គណបក្សកម្ពុជានិយម គណបក្សបេះដូងជាតិ និងគណបក្សឆន្ទៈខ្មែរ។[១០]

លោកសម រង្ស៊ី តាមរយៈទំព័រហ្វេសប៊ុក កាលពីថ្ងៃទី១៧ ខែកក្កដា បានចេញមកអំពាវនាវឱ្យ ពលរដ្ឋខ្មែរទាំងអស់ពិចារណាអំពីលទ្ធភាពបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិថ្មីមួយ នៅកម្ពុជាជាមួយរូប លោក។ លោកសម រង្ស៊ី ចង់ឱ្យមានការបង្កើតរដ្ឋាភិបាលនេះ ឱ្យដូចនៅក្នុងប្រទេសភូមាអ៊ីចឹងដែរ។ រំលង បាន២ថ្ងៃ លោកក៏បានចេញមកអំពាវនាវម្តងទៀត តែម្តងនេះ គឺអំពាវនាវដល់កងកម្លាំងប្រដាប់អាវុធ ឱ្យ ចូលរួមជាមួយលោក។ បើតាម លោក សម រង្ស៊ី ការបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិនាពេលនេះ គឺជា ពេលអំណោយផលនៃស្ថានការណ៍អន្តរជាតិ ដើម្បីរំដោះប្រទេសកម្ពុជាចេញពីរបបដែល លោក សម រង្ស៊ី អះអាងថា ផ្តាច់ការ ពុករលួយ និងក្បត់ជាតិ ដឹកនាំដោយ លោក ហ៊ុន សែន។

---

[៩] RFI, "តើបក្សថ្មីៗរបស់អតីតមន្ត្រីបក្សប្រឆាំង អាចបន្សាបឥទ្ធិពលរបស់លោក សម រង្ស៊ី និង លោក កឹម សុខា ឬទេ ?", August 8, 2021, https://rfi.my/7dkt, accessed date 8-August-2021 at 11 PM)

[១០] RFI, "លោក សុខ ឥសាន៖ បក្សគ្មានការបារម្ភអ្វីសោះចំពោះគម្រោងបង្រួមបង្រួម បង្កើតបក្សដោយមន្ត្រីជាន់ខ្ពស់នៃអតីតគណបក្សប្រឆាំង", August 6, 2021, https://rfi.my/7dRD, accessed date 8-August-2021 at 11 PM)

ចំណែក លោក កឹម សុខា បានប្រកាសឱ្យដឹងថា លោកមិនពាក់ព័ន្ធ មិនគាំទ្រ និងមិនចូលរួមក្នុងការគ្រោង និងការបង្កើតរដ្ឋាភិបាលក្រៅប្រទេស ដែលប្រកាសដោយ លោក សម រង្ស៊ី កាលពីពេលថ្មីៗនេះទេ។ ការប្រកាសរបស់ លោក កឹម សុខា នេះ ត្រូវបង្ហាញឱ្យដឹងជាសាធារណៈដោយ លោក ចាន់ ចេន ជាមេធាវី និងជាសហការីម្នាក់របស់លោក តាមរយៈបណ្ដាញសង្គមហ្វេសប៊ុកកាលពីថ្ងៃសៅរ៍។ មិនតែប៉ុណ្ណោះ លោកមេធាវី ចាន់ ចេន ថែមទាំងគូសបញ្ជាក់ឱ្យដឹងទៀតថា លោក កឹម សុខា ក៏មិនអនុញ្ញាតឱ្យយកឈ្មោះរបស់លោកទៅប្រើប្រាស់ និងភ្ជាប់ជាមួយរដ្ឋាភិបាលបង្រួបបង្រួមជាតិ នៅក្រៅប្រទេសរបស់លោក សម រង្ស៊ី ដែរ។[១១]

លោក សុខ ឥសាន បានចាត់ទុកថា វាគ្រាន់តែអាចបង្កើតបានត្រឹមតែជារដ្ឋាភិបាលនៅក្នុងអារម្មណ៍ប៉ុណ្ណោះ ហើយលោកថា អ្នកដែលឡើងធ្វើជាប្រធានរដ្ឋាភិបាលនេះ នឹងត្រូវឯកោពីពិភពលោក។ លោកសុខ ឥសាន ក៏ធ្លាប់បានគូសបញ្ជាក់នាពេលកន្លងមកថា ករណីប្រទេសកម្ពុជា និងប្រទេសភូមា គឺមិនដូចគ្នាសូម្បីតែបន្តិចឡើយ។

## ស្ថានភាពពីខាងក្រៅ

នៅខាងបច្ចិមប្រទេស ពិសេសសហរដ្ឋអាម៉េរិក ព្យាយាមដាក់សម្ពាធមករដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញឱ្យបក្សប្រឆាំង មានវត្តមានឡើងវិញ បើទោះបីក្រុមនេះត្រូវបានរំលាយ ដោយតុលាការកំពូល កាលពីខែវិច្ឆិកា ឆ្នាំ២០១៧ ពីបទរួមចំណែកជាមួយបរទេសក្នុងផែនការផ្តួលរំលំ រដ្ឋាភិបាលក៏ដោយ។

ការលើកឡើងដដែលៗរបស់សហរដ្ឋអាម៉េរិក នូវបញ្ហាដែលថា កម្ពុជាអនុញ្ញាតឱ្យមានវត្តមាននៃកងទ័ពចិន នៅកំពង់ផែសមុទ្ររាម បើទោះបីជាជាគុពិតគ្មានក៏ដោយ។

ចំណែកសមាជិកសភាសហរដ្ឋអាម៉េរិក បានលើកយកសេចក្តីព្រាងច្បាប់ដាក់ទណ្ឌកម្មលើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់មួយចំនួន ជុំវិញការធ្វើឱ្យខូចខាតលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពី«ប្រជាធិបតេយ្យកម្ពុជាឆ្នាំ២០២១» សមាជិកសភាអាម៉េរិកគ្រោងរុញបន្តទៅស្ថាប័នព្រឹទ្ធសភាដើម្បីពិនិត្យអនុម័តនៅពេលឆាប់ៗខាងមុខ។ លោក Steve Chabot ដែលជា សមាជិកសភា និងជាអ្នករៀបចំសេចក្តីព្រាងច្បាប់នេះ បានលើកឡើង នៅក្នុងសេចក្តីប្រកាសព័ត៌មានថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងថ្នាក់ដឹកនាំមួយចំនួនទៀត ត្រូវប្រឈមមុខ

[១១] RFI, "មេធាវីថា លោកកឹម សុខា មិនគាំទ្រ និងមិនពាក់ព័ន្ធក្នុងគម្រោងបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិរបស់លោកសម រង្ស៊ី", August 6, 2021, https://rfi.my/7dm1, accessed date 8-August-2021 at 11 PM)

នឹងផលវិបាកដ៏ធំពីសហរដ្ឋអាម៉េរិក ក្នុងការឆ្លើយតបទៅនឹងការចាប់ខ្លួន លោក កឹម សុខា និងការរំលាយគណបក្សប្រឆាំង នៅឆ្នាំ២០១៧ ដែលជាការបង្ក្រាបរហូតដល់មកសព្វថ្ងៃ។[១២]

ការលើកឡើងរបស់លោកស្រី មីស្សែល បាស្សេឡេត ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងកិច្ចប្រជុំលើកទី៤៦នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃសុក្រ ទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ «ខ្ញុំមានកង្វល់ជាពិសេសអំពីការធ្លាក់ចុះយ៉ាងខ្លាំងនូវ លំហាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា ដែលវិធានការច្បាប់ និងរដ្ឋបាល មិនសមាមាត្រ កំពុងកើនឡើង កំណត់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី ការចងក្រងសមាគម និងព័ត៌មាន ក្នុងចំណោម បញ្ហាផ្សេងៗទៀត»។[១៣]

ជាសរុបមក ទាំងបញ្ហាស្ថានភាពផ្ទៃក្នុងប្រទេស ទាំងពីមជ្ឈដ្ឋានអន្តរជាតិនានា សុទ្ធតែព្យាមធ្វើយ៉ាងណាដើម្បីឱ្យបក្សប្រឆាំង បានវិលត្រឡប់មកនៅលើឆាកនយោបាយដូចដើមវិញ ដោយយកលេសទាក់ទងនឹងបញ្ហាសិទ្ធមនុស្ស ខ្វះតម្លាភាព គ្មានយុត្តិធម៌ មិនមែនជាការបោះឆ្នោតតាមបែបប្រជាធិបតេយ្យក៏ដូចជាការដាក់ទណ្ឌកម្មនានា។ ប៉ុន្តែទោះជាយ៉ាងណាក្តី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ត្រូវបានប្រមុខរាជរដ្ឋាភិបាល កំណត់ជ្រើសយក ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខដែលជាកាតូកិច្ចរបស់រដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តន៍សម្រាប់រៀងរាល់៥ឆ្នាំម្តង ហើយបើទោះបីជាមានសម្ពាធ ដោយសារតែបញ្ហារីករាលដាល នៃវីរុសកូវីដ-១៩ផង បញ្ហានៃការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលផង បញ្ហានៃការប្រកួតប្រជែងអំណាចរវាងមហាអំណាចចិន-អាម៉េរិកផង គឺកម្ពុជានៅតែបន្តធ្វើ។ ទោះបីជាមានវត្តមាន ឬគ្មានវត្តមាន របស់បក្សប្រឆាំងក្នុងការបោះឆ្នោតអាណត្តិទី៥ខាងមុខ ក៏ពិតជាមិនធ្វើឱ្យចរន្តនយោបាយ របស់កម្ពុជាមានការផ្លាស់ប្តូរនោះដែរ ព្រោះវាជាបញ្ហាដែលកើតឡើងដដែលៗ ដែលប្រមុខរាជរដ្ឋាភិបាល ក៏ដូចជាថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា បានជួបប្រទះជាច្រើន អាណត្តិកន្លងរួចមកហើយ ហើយគណបក្ស សង្គ្រោះជាតិ ក៏ត្រូវបានរំលាយដោយអំណាចតុលាការ ហើយសមាជិកគណបក្សក៏បានបង្កើត គណបក្ស ថ្មីចំនួន៦រួចទៅហើយដែរ ដែលនេះជាសញ្ញានៃការបែកបាក់មួយ ដោយអស់ជំនឿលើអតីតមេដឹកនាំរបស់ខ្លួន។ ចំណែកអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ (Human Rights Watch) ដែលបានអះអាងថា ការបោះឆ្នោតឃុំ-សង្កាត់នៅប្រទេសកម្ពុជា កាលពីថ្ងៃទី៤ ខែមិថុនា

---

[១២] RFI, "សេចក្តីព្រាងច្បាប់ដាក់ទណ្ឌកម្មមន្ត្រីកម្ពុជាត្រូវបានសភាអាមេរិកលើកមកពិនិត្យអនុម័តឡើងវិញ", August 1, 2021, https://rfi.my/7cXI, accessed date 8-August-2021 at 11 PM)

[១៣] RFI, "មន្ត្រីសិទ្ធិមនុស្សUNថា កម្ពុជាកំពុងមានបញ្ហាសិទ្ធិមនុស្សធ្ងន់ធ្ងរ តែមន្ត្រីរដ្ឋាភិបាលច្រានចោល", March 2, 2021, https://rfi.my/7BGB, accessed date 8-August-2021 at 11 PM)

ឆ្នាំ២០១៧ បានប្រព្រឹត្តទៅក្នុង បរិយាកាសគំរាមកំហែងទៅដល់សិទ្ធិបញ្ចេញមតិ និងការចូលរួមក្នុងនយោបាយដែលអាចចាត់ទុក ការបោះឆ្នោតនេះថា មិនបានធ្វើឡើងដោយសេរី និងយុត្តិធម៌នោះ ក៏មិនមែនជាបញ្ហាអ្វីប្លែក ព្រោះថាអង្គការមួយនេះ មិនដែលបាននិយាយ ពីអ្វីដែលជាចំណុចល្អរបស់រដ្ឋាភិបាលកម្ពុជានោះដែរ។ ក្រោមការដឹកនាំ របស់ប្រមុខ រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ក៏ដូចជាថ្នាក់ដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា នៅតែអាចបោះជំហានទៅមុខ នៅតែត្រូវរក្សា និងរឹតចំណងមិត្តភាពក្នុងនាមជាអ្នកជិតខាងល្អបន្ថែមទៀត ក៏ដូចជាជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ និងជុំវិញពិភពលោក៕